# ការរង់ចាំនៅលើផ្លូវទៅកាន់ក្រុងដាម៉ាស

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីក្នុងគណៈប្រធានទីមួយ

*ពួកអ្នកដែលឧស្សាហ៍ក្នុងការស្វែងរកការរៀនសូត្រអំពីព្រះគ្រីស្ទ នឹងស្គាល់ទ្រង់នៅទីបំផុត ។*

ព្រឹត្តិការណ៍ដ៏គួរឲ្យកត់សម្គាល់បំផុតមួយក្នុងប្រវត្តិសាស្ត្រពិភពលោក បានកើតឡើងនៅលើផ្លូវទៅកាន់ក្រុងដាម៉ាស ។ អ្នកបានស្គាល់ច្បាស់ពីរឿងរបស់ សុល ជាយុវជនម្នាក់ដែលបាន « ធ្វើទុក្ខដល់ពួកជំនុំយ៉ាងខ្លាំង ដោយចូលគ្រប់តែផ្ទះ ... [ ចាប់ពួកបរិសុទ្ធ ] ទៅដាក់គុក » ។[1] សុលមានឥទ្ធិពលខ្លាំងណាស់ រហូតដល់មានសមាជិកជាច្រើននៃសាសនាចក្របានចាកចេញពី ក្រុងយេរូសាឡិម ដោយសង្ឃឹមថាអាចរត់គេចពីសេចក្ដីក្រោធរបស់សុលបាន ។

សុល បានតាមពួកគេ ។ ប៉ុន្តែ កាលដែលគាត់ « ទៅជិតនឹងដល់ក្រុងដាម៉ាសហើយ ... នោះស្រាប់តែមានពន្លឺពីលើមេឃ ភ្លឺមកនៅជុំវិញខ្លួន ៖ គាត់ក៏ដួលដល់ដី រួចឮសម្លេងមានបន្ទូលមកថា សុល នៃសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ ? »[2]

គ្រានេះបានផ្លាស់ប្តូរ សុល ជារៀងរហូត ។ តាមពិតទៅ វាបានផ្លាស់ប្តូរពិភពលោកតែម្តង ។

យើងដឹងថាមានការបើកសម្តែងបែបនេះកើតឡើង ។ ជាការពិត យើងធ្វើទីបន្ទាល់ថា បទពិសោធន៍ដ៏ទេវភាពស្រដៀងគ្នានេះ បានកើតឡើងក្នុងឆ្នាំ 1820 ចំពោះក្មេងប្រុសឈ្មោះ យ៉ូសែប ស្ម៊ីធ ។ វាគឺជាទីបន្ទាល់ដ៏ច្បាស់ និងប្រាកដរបស់យើង ថាស្ថានសួគ៌បានបើកម្តងទៀត ហើយថាព្រះមានព្រះបន្ទូលទៅកាន់ព្យាការី និងសាវករបស់ទ្រង់ ។ ព្រះឮ និងឆ្លើយតបការអធិស្ឋានរបស់កូនៗទ្រង់ ។

ទោះជាយ៉ាងណាក៏ដោយ ក៏មានមនុស្សខ្លះដែលមានអារម្មណ៍ថា ពួកគេមិនអាចជឿរឿងនេះបានទេ លើកលែងតែគេបានមានបទពិសោធន៍ស្រដៀងគ្នាទៅនឹងបទពិសោធន៍របស់ សុល ឬយ៉ូសែប ស្ម៊ីធ ។ ពួកគេឈរជិតទៅនឹងទឹកនៃបុណ្យជ្រមុជទឹក ប៉ុន្តែ មិនចុះចូលទេ ។ ពួកគេចំណាយថ្ងៃទាំងឡាយរបស់គេ រង់ចាំនៅលើផ្លូវទៅកាន់ក្រុងដាម៉ាស ។

**ការជឿមកមួយជំហានម្តងៗ**

បងស្រីជាទីស្រឡាញ់ម្នាក់ ជាសមាជិកដ៏ស្មោះត្រង់នៃសាសនាចក្រ អស់មួយជីវិតរបស់គាត់ ។ ប៉ុន្តែគាត់បានទទួលទុក្ខព្រួយដ៏អាថ៌កំបាំងមួយ ។ ជាច្រើនឆ្នាំមុន កូនស្រីរបស់គាត់បានស្លាប់ បន្ទាប់ពីធ្លាក់ខ្លួនឈឺក្នុងរយៈពេលដ៏ខ្លី ហើយរបួសដែលមកពីសោកនាដកម្មនេះ នៅតែញាំញីគាត់ ។ គាត់មានចិត្តសោកសៅចំពោះសំណួរដ៏ជ្រាលជ្រៅ ដែលមានចំពោះសោកនាដកម្មនេះ ។ មិនថាគាត់បានព្យាយាមយ៉ាងណានោះទេ ក៏គាត់មិនអាចយល់ពីវាឡើយ ។ គាត់បានសារភាពដោយត្រង់ថា ទីបន្ទាល់របស់គាត់មិនដូចពីមុននោះទេ ហើយទីបំផុតបានមានអារម្មណ៍ថា គាត់នឹងមិនដែលអាចជឿម្តងទៀតនោះទេ លើកលែងតែគាត់បានទទួលការបើកបង្ហាញពីស្ថានសួគ៌ ។គាត់បានឃើញថាគាត់រង់ចាំ ដោយពុំអាចឆ្ពោះទៅមុខបាន ហើយក៏មិនអាចជឿ ។

ដោយមូលហេតុផ្សេងៗ មានមនុស្សជាច្រើនទៀត ដែលឃើញថាពួកគេកំពុងរង់ចាំនៅលើផ្លូវទៅកាន់ក្រុងដាម៉ាស ។ ពួកគេពន្យារពេលក្នុងការក្លាយជាសិស្សដ៏ពេញលេញ ។ ពួកគេសង្ឃឹមថាបានទទួលបព្វជិតភាព ប៉ុន្តែស្ទាក់ស្ទើរក្នុងការរស់នៅឲ្យមានភាពសក្តិសមចំពោះឯកសិទ្ធិនោះ ។ ពួកគេប្រាថ្នាចង់ចូលព្រះវិហារបរិសុទ្ធ ប៉ុន្តែពន្យារពេលក្នុងការអនុវត្តន៍សេចក្តីជំនឿដើម្បីឲ្យមានភាពសក្តិសម ។ ពួកគេនៅតែរង់ចាំឲ្យព្រះគ្រីស្ទបញ្ជូនដល់ពួកគេ ដូចជារូបគំនូររបស់ ខាល ប្លក់ ដែលពណ៌នាពីការដកចេញនូវការសង្ស័យ និងការភ័យខ្លាចរបស់គេទាំងស្រុងតែម្តង ។

ការពិតនោះគឺថា ពួកអ្នកដែលឧស្សាហ៍ក្នុងការស្វែងរកការរៀនសូត្រអំពីព្រះគ្រីស្ទ នឹងស្គាល់ទ្រង់នៅទីបំផុត ។ ពួកគេនឹងទទួលរូបភាពដ៏ទេវភាពនៃលោកថៅហ្វាយ ដោយផ្ទាល់ខ្លួនគេ ។ ប៉ុន្តែ ញឹកញាប់បំផុតវាមកដូចជារូបផ្គុំអញ្ចឹង ---ម្តងមួយដុំៗ ។ ដុំនីមួយៗអាចមិនងាយស្រួលនឹងស្គាល់វាទេ---វាអាចមិនច្បាស់ ថាតើវាត្រូវភ្ជាប់ទៅនឹងរូបទាំងមូលយ៉ាងណានោះទេ ។ ប៉ុន្តែ ដុំនីមួយៗ ជួយយើងយល់កាន់តែច្បាស់ពីរូបភាពទាំងមូល ។ នៅទីបំផុត បន្ទាប់ពីមានដុំរូបភាពគ្រប់ហើយ នោះយើងនឹងដឹងពីភាពស្រស់ស្អាតដ៏អស្ចារ្យទាំងអស់របស់វា ។ បន្ទាប់មក ចូរក្រឡេកមើលទៅបទពិសោធន៍ទាំងឡាយ នោះយើង

ឃើញថា ព្រះអង្គសង្គ្រោះពិតជាបានយាងមកគង់ជាមួយយើងរហូត---មិនមកម្តងទាំងស្រុងនោះទេ ប៉ុន្តែ ដោយស្ងៀមស្ងាត់ ទន់ភ្លន់ ស្ទើរតែមិនអាចកត់សម្គាល់បាន ។ នេះអាចជាបទពិសោធន៍របស់យើង បើសិនជា យើងឈានឆ្ពោះទៅមុខដោយសេចក្តីជំនឿ និងមិនរង់ចាំយូរពេកនៅលើផ្លូវទៅកាន់ក្រុងដាម៉ាស ។

**៧ ហើយស្តាប់**

ខ្ញុំធ្វើទីបន្ទាល់ទៅអ្នកថា ព្រះវរបិតានៅស្ថានសួគ៌របស់យើង ស្រឡាញ់កូនៗរបស់ទ្រង់ ។ ទ្រង់ស្រឡាញ់អ្នក ។ ពេលចាំបាច់ព្រះអម្ចាស់នឹងបីអ្នក ឆ្លងកាត់ឧបសគ្គទាំងឡាយ ពេលដែលអ្នកស្វែងរកក្តីសុខសាន្តរបស់ទ្រង់ ដោយចិត្តសោកសង្រេង និងវិញ្ញាណទន់ទាប ។ ជាញឹកញាប់ ទ្រង់មានបន្ទូលមកកាន់យើង នៅក្នុងរបៀបទាំងឡាយដែលយើងអាចឮដោយដួងចិត្តរបស់យើងប៉ុណ្ណោះ ។ ដើម្បីឮសម្លេងទ្រង់កាន់តែច្បាស់ ជាការឆ្លាតវៃបើយើងបន្ថយសម្លេងនៃលោកិយដែលនៅក្នុងជីវិតរបស់យើង ។ បើយើងមិនអើពើ ឬបង្ខាំងការបំផុសនៃព្រះវិញ្ញាណ ដោយមូលហេតុអ្វីក៏ដោយ នោះការបំផុសនោះ កាន់តែពិបាកក្នុងការកត់សម្គាល់ រហូតទាល់តែយើងលែងឮតែម្តង ។ ចូរយើងរៀនស្តាប់ការបំផុសនៃព្រះវិញ្ញាណ ហើយបន្ទាប់មកស្រែកឃ្លានក្នុងការស្តាប់ការបំផុសទាំងនោះ ។

ព្យាការីជាទីស្រឡាញ់របស់យើង ថូម៉ាស អេស ម៉នសុន ជាគំរូរបស់យើងក្នុងរឿងនេះ ។ មានរឿងជាច្រើននៃការយកចិត្តទុកដាក់របស់គាត់ចំពោះការខ្សឹបរបស់ព្រះវិញ្ញាណ ។ អែលឌើរ ហូឡិន បានលើកឡើងគំរូមួយ ។

គ្រាមួយ ខណៈដែលប្រធាន ម៉នសុន ត្រូវបានចាត់តាំងទៅកាន់ លូស៊ីយ៉ាណា ប្រធានស្តេកម្នាក់បានសួរគាត់ បើសិនជាគាត់មានពេលទៅសួរសុខទុក្ខក្មេងស្រីអាយុ 10 ឆ្នាំម្នាក់ ឈ្មោះ គ្រីស្តាល់ ដែលស្ថិតនៅក្នុងដំណាក់កាលចុងក្រោយនៃជំងឺមហារីក ។ ក្រុមគ្រួសាររបស់គ្រីស្តាល់ បានអធិស្ឋានដើម្បីឲ្យប្រធាន ម៉នសុន មក ។ ប៉ុន្តែ ផ្ទះរបស់គេឆ្ងាយណាស់ ហើយកាលវិភាគចង្អៀតណាស់ មិនអាចមានពេលនោះទេ ។ ដូច្នេះ ជំនួសឲ្យការសួរសុខទុក្ខប្រធាន ម៉នសុន បានសុំឲ្យអ្នកដែលអធិស្ឋាននៅក្នុងសន្និសីទស្តេក បញ្ចូល គ្រីស្តាល់ ទៅក្នុងការអធិស្ឋានរបស់គេ ។ ប្រាកដណាស់ ព្រះអម្ចាស់ និងក្រុមគ្រួសារនាងនឹងយល់ ។

អំឡុងពេល សម័យប្រជុំថ្ងៃ សៅរ៍ នៃសន្និសីទ ពេលដែលប្រធាន ម៉នសុន ឈរឡើងនិយាយ ព្រះវិញ្ញាណបានខ្សឹបថា « ទុកឲ្យក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធមនុស្សដូចវារាល់គ្នាដែរ » ។[3]

« កំណត់ត្រាសម្រាប់ការនិយាយរបស់គាត់បានក្លាយជាច្របូកច្របល់ ។ គាត់ចង់បន្តទៅលើប្រធានបទរបស់ការប្រជុំ ប៉ុន្តែ ឈ្មោះ និងរូបភាពរបស់ [ ក្មេងស្រីតូច ] មិនបានចេញពីគំនិតរបស់គាត់ទេ » ។[4]

គាត់បានស្តាប់តាមព្រះវិញ្ញាណ ហើយបានរៀបចំកាលវិភាគគាត់ឡើងវិញ ។ ព្រឹកព្រលឹមបន្ទាប់នោះ ប្រធាន ម៉នសុន ទុកចៀមទាំង 99 ហើយបានធ្វើដំណើរជាច្រើនគីឡូម៉ែត្រ ដើម្បីទៅនៅក្បែរចៀមមួយដែលត្រូវការជំនួយ ។

ពេលទៅដល់ទីនោះ គាត់ « បានសម្លឹង » ទៅកាន់ក្មេងតូចដែលឈឺធ្ងន់មិនរួច ខ្សោយពេកមិនអាចនិយាយបាន ។ ជំងឺរបស់នាងបានធ្វើឲ្យនាងមិនអាចមើលឃើញទេ ។ ដោយបានប៉ះទៅក្នុងចិត្តយ៉ាងជ្រៅ ដោយព្រះវិញ្ញាណ នោះបងប្រុស ម៉នសុន បានចាប់ដៃដ៏ទន់ខ្សោយរបស់ក្មេងតូចកាន់ក្នុងដៃគាត់ ។ គាត់បានខ្សឹបថា ‹ គ្រីស្តាល់ ខ្ញុំនៅទីនេះហើយ › ។ ដោយខំប្រឹងយ៉ាងខ្លាំង នាងបានខ្សឹបត្រឡប់មកវិញថា ‹ បងប្រុស ម៉នសុនខ្ញុំដឹងថាលោកនឹងមក › » ។[5]

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ចូរយើងព្យាយាមនៅក្នុងចំណោមពួកអ្នកដែលព្រះអម្ចាស់អាចពឹងពាក់បាន ដើម្បីឮការខ្សឹបរបស់ទ្រង់ ហើយឆ្លើយតប ដូចជា សុល បានធ្វើនៅលើផ្លូវ *គាត់* ទៅកាន់ក្រុងដាម៉ាស « ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្តេច ? »[6]

**បម្រើ**

មូលហេតុមួយទៀត ដែលជួនកាល យើងមិនបានស្គាល់ពីសម្លេងព្រះអម្ចាស់ នៅក្នុងជីវិតរបស់យើង គឺដោយសារតែវិវរណៈនៃព្រះវិញ្ញាណអាចមិនមកកាន់យើងផ្ទាល់ក្នុងសណ្ឋានជាចម្លើយដល់ការអធិស្ឋានរបស់យើងនោះទេ ។

ព្រះវរបិតានៅស្ថានសួគ៌ រំពឹងឲ្យយើងសិក្សាវាសិន ហើយបន្ទាប់មកអធិស្ឋានសុំការណែនាំ កាលដែលយើងស្វែងរកចម្លើយ ចំពោះសំណួរ និងកង្វល់ទាំងឡាយ នៅក្នុងជីវិតផ្ទាល់ខ្លួនយើង ។ យើងមានការធានាអះអាងពីព្រះវរបិតាថា ទ្រង់នឹងឮ ហើយឆ្លើយតបការអធិស្ឋានរបស់យើង ។ ចម្លើយអាចមកតាមរយៈសម្លេង និងប្រាជ្ញា នៃមិត្ត និងគ្រួសារដែលយើងទុកចិត្ត តាមព្រះគម្ពីរ តាមពាក្យសម្ដីនៃព្យាការី ។

វាជាបទពិសោធន៍របស់ខ្ញុំ ថាការបំផុសដ៏មានអំណាចបំផុតមួយចំនួន ដែលយើងទទួល មិនត្រឹមតែជាប្រយោជន៍សម្រាប់យើងផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ជាប្រយោជន៍អ្នកដទៃផងដែរ ។ បើសិនជា យើងគិតតែពីខ្លួនឯង យើងអាចបាត់បង់បទពិសោធន៍ខាងវិញ្ញាណដ៏មានអំណាចបំផុតមួយចំនួន និងវិវរណៈដ៏ជ្រាលជ្រៅ នៅក្នុងជីវិតរបស់យើង ។

ប្រធាន ឃឹមបឹល បានបង្រៀនពីគំនិតនេះថា « ព្រះកត់សម្គាល់យើង ហើយទ្រង់មើលថែយើង ។ ប៉ុន្តែ ជាធម្មតា គឺតាមរយៈមនុស្សផ្សេងទៀត ដែលទ្រង់ឆ្លើយតបតម្រូវការរបស់យើង ។ ហេតុដូច្នេះហើយ សំខាន់ណាស់ថាយើងត្រូវបម្រើគ្នាទៅវិញទៅមក » ។[7] បងប្អូនប្រុសស្រី យើងម្នាក់ៗមាននូវការទទួលខុសត្រូវក្នុងសេចក្ដីសញ្ញា ដើម្បីដឹងពីសេចក្ដីត្រូវការរបស់អ្នកដទៃទៀត ហើយបម្រើ ដូចជាព្រះអង្គសង្គ្រោះបានធ្វើ ដើម្បីឈោងទៅ ផ្ដល់ពរជ័យ និងលើកអ្នកនៅជុំវិញយើងឡើង ។

ជួនកាល យើងមិនអើពើចំពោះការបំផុសដ៏សំខាន់ ព្រោះការបំផុតនោះមិនលេចឡើងជាចម្លើយដោយផ្ទាល់ចំពោះការអធិស្ឋានរបស់យើង ។ ប៉ុន្តែ វាអាចជាចម្លើយយ៉ាងល្អសម្រាប់ការអធិស្ឋានរបស់នរណាម្នាក់ផ្សេងទៀត ។

ជាញឹកញាប់ ចម្លើយចំពោះការអធិស្ឋានរបស់យើង មិនបានមក នៅពេលយើងលុតជង្គង់នោះទេ ប៉ុន្តែ ពេលដែលយើងឈានជើងរបស់យើង ដើម្បីបម្រើព្រះអម្ចាស់ និងអ្នកដែលនៅជុំវិញយើង ។ ការបម្រើ និងការបូជាដោយមិនគិតពីខ្លួនឯង ដុសខាត់វិញ្ញាណរបស់យើង យកស្រកាចេញពីភ្នែកខាងវិញ្ញាណរបស់យើង ហើយបើកបង្អួចស្ថានសួគ៌ ។ ដោយធ្វើជាចម្លើយចំពោះអធិស្ឋានរបស់អ្នកផ្សេងទៀត នោះជាញឹកញាប់ យើងក៏រកឃើញចម្លើយសម្រាប់ខ្លួនយើងផងដែរ ។

**ចែកចាយ**

មានពេល ដែលព្រះអម្ចាស់បើកបង្ហាញដល់យើងនូវការណ៍ខ្លះដែលគ្រាន់តែសម្រាប់យើងប៉ុណ្ណោះ ។ យ៉ាងណាក៏ដោយ ក្នុងករណីជាច្រើន ទ្រង់ផ្ដុកទីបន្ទាល់នៃសេចក្ដីពិតដល់ពួកអ្នកដែលទ្រង់ដឹងថា នឹងចែកចាយជាមួយអ្នកដទៃ ។ នេះជាករណីសម្រាប់គ្រប់ព្យាការី តាំងពីជំនាន់លោកអ័ដាមមក ។ ព្រះអម្ចាស់ក៏រំពឹងឲ្យយើងជាសមាជិកនៃសាសនាចក្រដែលបានស្ដារឡើងវិញរបស់ទ្រង់ឲ្យ « បើក [ មាត់របស់យើង ] គ្រប់ពេល ហើយប្រកាសប្រាប់ពីដំណឹងល្អ [ របស់ទ្រង់ ] ដោយសម្លេងរីករាយចុះ » ។[8]

មិនតែងតែងាយស្រួលនោះទេ ។ អ្នកខ្លះសុខចិត្តទាញរទេះរាប់ពាន់គីឡូម៉ែត្រកាត់វាលស្មៅដ៏ធំ ជាជាងលើកឡើងពីប្រធានបទពីជំនឿ និងសាសនា ទៅកាន់មិត្តភ័ក្តិ និងមិត្តរួមការងាររបស់គេ ។ គេបារម្ភថាគេត្រូវថ្កោលទោស ឬវាអាចបំផ្លាញទំនាក់ទំនងរបស់គេ ។ វាមិនចាំបាច់តាមរបៀបនោះទេ ព្រោះយើងមានដំណឹងដ៏រីករាយមួយដើម្បីចែកចាយ---ដំណឹងនៃសេចក្ដីអំណរ ។

ច្រើនឆ្នាំកន្លងមកហើយ គ្រួសាររបស់យើងបានរស់នៅ និងធ្វើការក្នុងចំណោមមនុស្សដែលមិននៅក្នុងក្ដីជំនឿដូចយើង ។ ពេលគេសួរយើងថា ចុងសប្ដាហ៍យ៉ាងម៉េចដែរ យើងបានព្យាយាមជៀសវាងពីប្រធានបទធម្មតា ---ដូចជា កីឡា កុន ឬអាកាសធាតុ ---ហើយព្យាយាមចែកចាយពីបទពិសោធន៍ខាងសាសនាដែលយើងមាននៅចុងសប្ដាហ៍ ក្នុងនាមជាគ្រួសារមួយ ។ ចែកចាយពីអ្វីដែលយុវវ័យនិយាយនៅម៉ោងសាក្រាម៉ង់ពីបទដ្ឋានពីសៀវភៅ *ដើម្បីកម្លាំងនៃយុវវ័យ* ឬពីរបៀបដែលយើងត្រូវបានដក់ជាប់ដោយពាក្យសម្ដីរបស់យុវជនម្នាក់ដែលចេញទៅបម្រើបេសកកម្ម ឬពីរបៀបដែលដំណឹងល្អ និងសាសនាចក្របានជួយគ្រួសារយើងយកឈ្នះឧបសគ្គនានា ។

យើងពុំចាំបាច់ព្យាយាមធ្វើឲ្យដូចជាទេសនាពេកនោះទេ ។ ភរិយារបស់ខ្ញុំ ហារីត តែងតែពូកែបំផុតក្នុងការរកអ្វីដែលបំផុសគំនិត លើកឡើង ឬដែលកំប្លែង ដើម្បីចែកចាយ ។ ជាញឹកញាប់ វានាំទៅកាន់ការពិភាក្សាដ៏ស៊ីជម្រៅ ។ គួរឲ្យចាប់អារម្មណ៍ រាល់ពេលដែលយើងបាននិយាយជាមួយមិត្តភ័ក្តិយើងពីការដោះស្រាយឧបសគ្គក្នុងជីវិត យើងបានឮជាញឹកញាប់នូវពាក្យថា « វាងាយសម្រាប់អ្នក ដែលអ្នកមានសាសនាចក្ររបស់អ្នក » ។

ដោយមានធនធានបណ្ដាញផ្សព្វផ្សាយខាងសង្គមជាច្រើន និងចំនួនដ៏ច្រើននៃគ្រឿងម៉ាស៊ីនដែលមានប្រយោជន៍ច្រើនក្តី តិចក្តី នោះការចែកចាយដំណឹងល្អគឺមានភាពងាយស្រួលជាងមុន ហើយក៏មានប្រសិទ្ធភាពទៅបានឆ្ងាយជាងមុនដែរ ។ តាមពិតទៅ ខ្ញុំខ្លាចថា មានអ្នកខ្លះដែលកំពុងស្ដាប់ពាក្យខ្ញុំថ្ងៃនេះ បានផ្ញើសារទៅកាន់មិត្តរបស់គេរួចទៅហើយ ដូចជាថា « គាត់និយាយ 10 នាទីទៅហើយ តែនៅមិនទាន់និយាយពីការបើកយន្តហោះនោះទេ ! » មិត្តវ័យក្មេងរបស់ខ្ញុំអើយ តើវាមិនជាការជំរុញរបស់ព្រះអម្ចាស់ទេឬ ថាឲ្យ « បើកមាត់របស់អ្នក »[9] នៅជំនាន់របស់យើងប្រហែលជាត្រូវរួមទាំង « ប្រើដៃរបស់អ្នក » ដើម្បីផ្ញើសារ សរសេរលើគេហទំព័រ នូវដំណឹងល្អនៃព្រះសិក្ខាបទ ! ប៉ុន្តែ សូមចងចាំថា ត្រូវធ្វើវានៅកន្លែង និងពេលវេលាដែលត្រឹមត្រឹម ។

បងប្អូនប្រុសស្រី ជាមួយនឹងពរជ័យនៃបច្ចេកវិជ្ជាដ៏ទំនើប នោះយើងសូមបង្ហាញនូវការដឹងគុណ និងសេចក្ដីអំណរ ចំពោះផែនការណ៍ដ៏អស្ចារ្យរបស់ព្រះសម្រាប់កូនៗរបស់ទ្រង់ ដែលបានឮ មិនត្រឹមតែជុំវិញកន្លែងនេះប៉ុណ្ណោះទេ ប៉ុន្តែ ជុំវិញពិភពលោក ។ ជួនកាល ទីបន្ទាល់តែមួយឃ្លា អាចឲ្យព្រឹត្តិការណ៍ទាំងឡាយចាប់ផ្ដើមកើតឡើង ដែលនឹងមានឥទ្ធិពលលើជីវិតនរណាម្នាក់សម្រាប់ភាពអស់កល្បជានិច្ច ។

វិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្សាយដំណឹងល្អ គឺតាមរយៈគំរូ ។ បើយើងរស់នៅតាមអ្វីដែលយើងជឿ នោះមនុស្សនឹងកត់សម្គាល់ ។ បើព្រះភក្ត្ររបស់ព្រះយេស៊ូវគ្រីស្ទ រះពន្លឺនៅក្នុងជីវិតរបស់យើង[10] បើយើងរីករាយ និងមានសន្តិភាពជាមួយពិភពលោក នោះមនុស្សនឹងចង់ដឹងថាហេតុអ្វី ។ ធម្មទេសនាដ៏អស្ចារ្យមួយ អំពីកិច្ចការផ្សព្វផ្សាយសាសនា គឺគំនិតដ៏សាមញ្ញមួយ ដែលបានថ្លែងដោយ សេន ហ្វ្រេនស៊ីស នៃ អាស៊ីស៊ី ថា ៖ « ប្រកាសដំណឹងល្អដោយការប្រព្រឹត្តគ្រប់ពេលទាំងអស់ ហើយបើចាំបាច់ ប្រើពាក្យសម្ដីផង » ។ ឱកាសដើម្បីធ្វើដូច្នោះមាននៅជុំវិញខ្លួនយើង ។ កុំរំលងឱកាសនោះ ដោយការរង់ចាំយូរពេកនៅលើផ្លូវទៅកាន់ក្រុងដាម៉ាស ។

**ផ្លូវនៃភាពជាសិស្ស**

ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់មានបន្ទូលទៅកាន់ព្យាការី និងសាវករបស់ទ្រង់នៅសព្វថ្ងៃនេះ ។ ទ្រង់ក៏មានបន្ទូលទៅកាន់អស់អ្នកដែលមកឯទ្រង់ ដោយចិត្តស្មោះស និងស្មោះអស់ពីចិត្ត ។ [11]

កុំមានការសង្ស័យឡើយ ។ ចូរចងចាំ « មានពរហើយ អ្នកណាដែលជឿ ឥតឃើញសោះ » ។ [12] ព្រះស្រឡាញ់អ្នក ។ ទ្រង់ឮការអធិស្ឋានរបស់អ្នក ។ ទ្រង់មានបន្ទូលមកកាន់កូនៗរបស់ទ្រង់ និងផ្ដល់ការលួងលោម ក្ដីសុខសាន្ត និងការយល់ដឹង ដល់ពួកអ្នកដែលរកទ្រង់ និងគោរពទ្រង់ ដោយដើរតាមមាគ៌ារបស់ទ្រង់ ។ ខ្ញុំថ្លែងនូវទីបន្ទាល់ដ៏ពិសិដ្ឋរបស់ខ្ញុំថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺដើរតាមគន្លងនៃព្រះ ។ សាសនាចក្រត្រូវបានដឹកនាំដោយទ្រង់ ដែលយើងថ្លែងពីព្រះនាមទ្រង់ ជាព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ។

ចូរយើងកុំរង់ចាំយូរពេកនៅលើផ្លូវ *របស់យើង* ទៅកាន់ក្រុងដាម៉ាស ចូរយើងឈានទៅមុខដោយក្លាហាន នៅក្នុងសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ហើយយើងនឹងត្រូវបានប្រទានពរ ឲ្យរកឃើញនូវពន្លឺ ដែលយើងទាំងអស់គ្នាកំពុងស្វែងរក នៅលើផ្លូវនៃភាពជាសិស្ស ។ ខ្ញុំថ្លែងទីបន្ទាល់នេះ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1.កិច្ចការ 8:3 ។

2. កិច្ចការ 9:3—4 ។

3. ម៉ាកុស 10:14 ។

4. Jeffrey R. Holland « President Thomas S. Monson: Man of Action, Man of Faith, Always 'on the Lord's Errand' » Ensign ខែ កុម្ភៈ ឆ្នាំ 1986 ឆ្នាំ 16 ។

5. Jeffrey R. Holland « President Thomas S. Monson » ទំព័រ 16 ។

6. កិច្ចការ 9:6 ។

7. Spencer W. Kimball « Small Acts of Service » Ensign ខែ ធ្នូ ឆ្នាំ 1974 ទំព័រ 5 ។

8. គោលលទ្ធិ និងសេចក្ដីសញ្ញា 28:16 ។

9. គោលលទ្ធិ និងសេចក្ដីសញ្ញា 60:2 ។

10. សូមមើល អាលម៉ា 5:14 ។

11. សូមមើល មរ៉ូណៃ 10:3—5 ។

12. យ៉ូហាន 20:29 ។